# ផ្ទះប៉ិត

ជាប្រភេទផ្ទះមានដំបូលផ្គុំឡើងដោយប្រើជញ្ជាំងឈើ៤ផ្ទាំង មានកម្ពស់ស្មើគ្នាដូចរាងការ៉េ តែផ្ទះប៉ិតខ្លះអាចមានជញ្ជាំងទ្រវែងនៅផ្នែកខាងមុខ និងផ្នែកខាងក្រោយ ដូចជារាងចតុកោណកែង ហើយនៅផ្នែកដំបូល គឺពុំមានហោជាងដូចប្រភេទផ្ទះកិងនោះទេ (រូបលេខ១-២)។ ផ្ទះប៉ិត បើមើលប្លង់ផ្ទះឃើញថា មានទ្វារមួយនៅចំកណ្តាលនៃជញ្ជាំងផ្ទះមានរាងទ្រវែងទំហំធំជាងគេ។ ផ្ទះប្រភេទនេះអាចពង្រីកបន្ថែមដំបូលបាន ប៉ុន្តែជាធម្មតាមានត្រឹមពីរខ្នង ហើយជួនកាលគេអាចពង្រីកបញ្ចូលគ្នាមានច្រើនរហូតដល់ប្រាំខ្នងក៏មាន។ ពាក្យថា "ប៉ិត" មានន័យថា អារ ចិត កាប់ ឬកាត់ ឧទាហរណ៍ អារឱ្យដាច់ប៉ិត កាត់ឱ្យប៉ិត ឬកាប់ឱ្យប៉ិត ចិតឱ្យប៉ិតជាដើម ដែលជាការនិយាយសាមញ្ញរបស់អ្នកស្រុក តែម្តងម្កាលក៏ធ្លាប់ឮអ្នកទីក្រុងនិយាយខ្លះដែរ។ ន័យមួយបែបទៀត ដែលសំដៅទៅឈ្មោះប្រភេទផ្ទះមួយផ្សេងពីផ្ទះកន្តាំង និងផ្ទះរោងដោល គឺមានសណ្ឋានដូចគេប៉ិតត្រង់ចុងមេដំបូលទាំងពីរសង្ខាង ដែលគេឱ្យឈ្មោះថា "ផ្ទះប៉ិត"។[1]

នៅសម័យអាណានិគមបារាំង អំឡុងស.វទី១៩ ប្រភេទផ្ទះប៉ិតនេះមានប្រជាប្រិយភាពខ្លាំង ជាក់ស្តែងក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ និងព្រះបាទស៊ីសុវត្ថិមុនីវង្ស[2] ប្រជាជនខ្មែរសម័យនោះ និយមសង់ផ្ទះប៉ិតគ្មានហោជាងមុខក្រោយឡើយ និងក្រោយមកទៀតសំណង់ផ្ទះប៉ិតបានវិវត្តពីសំណង់ជាសសរ២ជួរ ថែមទៅជាសសរបីជួរ ដើម្បីពង្រីកផ្ទៃផ្ទះឱ្យធំទូលាយ។ លុះមកដល់រជ្ជកាលព្រះបាទសម្តេចនរោត្តមសីហនុ[3] ខ្មែរនៅតែនិយមសង់ផ្ទះប៉ិតនេះច្រើនខ្នង ក្នុងនោះមានផ្ទះធំមួយខ្នង ផ្ទះបាយមួយខ្នង និងហោណាំងមុខមួយខ្នងដែលសង់ស្ទើរតែទាំងពាសពេញប្រទេសកម្ពុជា រីឯជនជាតិចាម ជ្វាក៏និយមធ្វើផ្ទះប៉ិតនេះដែរ។

ផ្ទះប៉ិត ជាទូទៅគឺមានការនិយមសង់ច្រើនពីអ្នកភូមិ បើយើងសង្កេតមើលតាមភូមិស្រុកមួយចំនួនក្នុងស្រុកខ្មែរ ដ្បិតអីផ្ទះប្រភេទនេះ គេងាយស្រួលសាងសង់ ដោយវាពុំមាន

---

[1] ជួន ណាត ១៩៦៧

[2] អួង វន ២០០១: ២៧

[3] អួង វន ២០០១: ២៧

អត្ថបទដោយ៖ **លោក ថាន់ មនោមយិទ្ធិ**

រចនាសម្ព័ន្ធសាំរញ៉ាំច្រើន និងត្រូវចំណាយឈើច្រើនលើការរចនាដំបូល[៦] ព្រមទាំងអាចជួសជុលសង់បន្ទប់បន្ថែមបានយ៉ាងងាយស្រួលតាមតម្រូវការរបស់អ្នកភូមិ។

នៅសម័យដើមសំណង់ផ្ទះប៉ិត ពិតជាល្អប្រណិតណាស់ រួមទាំងគ្រឿងតុបតែងលម្អក្នុងផ្ទះ ដោយម្ចាស់ផ្ទះសុទ្ធតែមានទ្រព្យសម្បត្តិ និងឋានៈខ្ពង់ខ្ពស់ជាអ្នកសាងសង់ ឧទាហរណ៍ លោក ឧកញ៉ា ពិនិត្យ ភឹង សង់ផ្ទះប៉ិតនៅខេត្តបាត់ដំបង និងដង្ហោ ស៊ុន ហ៊ី សង់ផ្ទះប៉ិតនៅខេត្តក្រចេះជាដើម។ លុះមកដល់សព្វថ្ងៃនេះ សង្កេតឃើញមាននៅសល់សំណង់ផ្ទះប៉ិតខ្លះដែរ ដែលស្ថិតនៅតាមបណ្តាខេត្តនានានៅក្នុងស្រុកខ្មែរ ដូចជានៅខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកណ្តាលជាដើម(រូបលេខ២៣)។ តែសំណង់ទាំងនោះ ខ្លះនៅល្អរឹងមាំដោយការថែរក្សាជិតដល់ពីម្ចាស់ផ្ទះ ខ្លះទៀតមានសភាពទ្រុតទ្រោមខ្លាំង ដោយសារអាយុកាលនៃសំណង់ឈើ ដ្បិតអីសំណង់ឈើងាយនឹងទទួលរងការពុកផុយណាស់។ ម្យ៉ាងទៀត សំណង់ផ្ទះប៉ិតខ្លះត្រូវម្ចាស់រុះរើ ដោយស្ថានភាពផ្ទះទ្រុតទ្រោម ឬអាចម្ចាស់ផ្ទះមានលទ្ធភាព និងបំណងចង់សាងសង់ផ្ទះបែបរចនាបថបច្ចុប្បន្ន(រូបលេខ២៨)។

សម្រាប់សំណង់ផ្ទះប៉ិត និងប្រភេទសំណង់ផ្ទះបុរាណផ្សេងៗទៀត ដែលនៅរឹងមាំល្អជាពិសេសផ្ទះបុរាណខ្មែរនៅខេត្តបាត់ដំបង និងក្រចេះ គឺជាទិសដៅសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍បែបប្រវត្តិសាស្ត្រ ឱ្យមកស្គាល់ពីសំណង់ផ្ទះបុរាណ ក៏ដូចជាសំណង់ស្ថាបត្យកម្មផ្ទះខ្មែរដ៏អស្ចារ្យ ឧទាហរណ៍ផ្ទះប៉ិតបុរាណរបស់លោកយាយ ប៊ុន រឿង សង់ឡើងនៅឆ្នាំ១៩២០ ដែលបច្ចុប្បន្នបើកបម្រើឱ្យភ្ញៀវទេចរណ៍ចូលមកទស្សនា ពីឧបករណ៍ប្រើប្រាស់សម្រាប់ការងារកសិកម្ម សិប្បកម្មតម្បាញ ក្បូរក្បាច់រចនាលំនៅដ្ឋានដែលជារចនាបថខ្មែរបុរាណសុទ្ធសាធ។ ម្យ៉ាងទៀត ការមកដល់របស់ភ្ញៀវទេចរណ៍ទាំងនេះ ក៏អាចជួយអភិវឌ្ឍជីវភាពរបស់សហគមន៍ក្នុងភូមិស្រុក និងបង្កើនការយល់ដឹងដល់អ្នកស្រុកក្នុងការចូលរួមការពារ និងអភិរក្សសំណង់ផ្ទះបុរាណខ្មែរឱ្យបានយូរអង្វែងសម្រាប់កូនចៅជំនាន់ក្រោយបានស្គាល់។

[៦] Lormaneenopparat 2008: 30





រូបលេខ១-២៖ ទម្រង់ផ្ទះប៉ិត



រូបលេខ៣៖ ផ្ទះប៉ិតនៅខេត្តបាត់ដំបង និងជាកន្លែងទាក់ទាញភ្ញៀវទេសចរណ៍



រូបលេខ៤៖ ផ្ទះប៉ិតរុះរើដោយសង់បែបរចនាបថសម័យថ្មី

អត្ថបទដោយ៖ លោក ថាន់ មនោមយិទ្ធិ

# ឯកសារយោង

**ជួន ណាត**

១៩៦៧. "វចនានុក្រមខ្មែរ, បោះពុម្ពលើកទី៥, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

**អួង វន**

២០០១. "លំនៅដ្ឋានបុរាណខ្មែរក្នុងការអភិវឌ្ឍន៍",ទំព័រ ២៧, ភ្នំពេញ។

**Sarunya Lormaneenopparat.**

2008. *" Khmer Traditional House and Landscape Conservation Khoh Dach Commune, Muk Kam Poul District, Kandal Province, Cambodia",* UNESCO FELLOWSHIP AWARD PROGRAM (2006-2007) In support of priority program areas, Cambodia, pp.30.

# ប្រភពរូបភាព

- https://www.battambang.gov.kh/detail/849
- គេហទំព័របច្ចេកវិទ្យា និងព័ត៌មានសំណង់
- រូបឯកជន